# សហគមន៍ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

លេខ [illegible] ស.ខ.ក.ក.

## គោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

*__កម្មវត្ថុ:__* ស្នើសុំ ពហុកីឡាដ្ឋានជាតិ អូឡាំពិច ធ្វើបុណ្យរាប់បាត្រព្រះសង្ឃ១៩៤៩អង្គ

*__យោង:__* លិខិតលេខ៣០៧ រត.អធិ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ របស់សាលារាជធានីភ្នំពេញ

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា កាលពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០ សហគមន៍ខ្មែរកម្ពុជាក្រោម បានធ្វើលិខិតជាផ្លូវការមួយច្បាប់ ស្នើសុំសាលារាជធានីភ្នំពេញ នៅទីតាំង ពហុកីឡាដ្ឋានជាតិ អូឡាំពិច រួចហើយ ហើយសាលារាជធានីក៏មិនមានការយល់ទាស់ដែរ ប៉ុន្តែសាលារាជធានីបានណែនាំឲ្យស្នើសុំទៅក្រសួងអប់រំ យុវជន និងកីឡា ថែមទៀត ព្រោះពហុកីឡាដ្ឋានជាតិអូឡាំពិច ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ដូច្នេះសហគមន៍ខ្មែរកម្ពុជាក្រោមមកដល់ពេលនេះ នៅពុំទាន់មានទីកន្លែងសមរម្យណាមួយ សំរាប់ប្រារព្ធពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន១៩៤៩អង្គ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ ខាងមុខនេះនៅឡើយទេ។

អាស្រ័យហេតុនេះ សហគមន៍ខ្មែរកម្ពុជាក្រោម សូមអនុញ្ញាតស្នើសុំឯកឧត្តមរដ្ឋមន្ត្រី នៅទីតាំងពហុកីឡាដ្ឋានជាតិអូឡាំពិច ដើម្បីរៀបចំធ្វើពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន១៩៤៩អង្គ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ខាងមុខ ដូចរៀងរាល់ឆ្នាំ។

សហគមន៍ខ្មែរកម្ពុជាក្រោមមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តមរដ្ឋមន្ត្រីពិតជាអនុញ្ញាត ទីកន្លែង ពហុកីឡាដ្ឋានជាតិ អូឡាំពិច ដល់សហគមន៍ខ្មែរកម្ពុជាក្រោម ដើម្បីប្រារព្ធពិធីបុណ្យដូចបានជំរាបជូនខាងលើជាក់ជាមិនខាន។

សូមឯកឧត្តម ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

*រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០*

[illegible]សហគមន៍ខ្មែរកម្ពុជាក្រោម

សេដ្ឋា

ក្រុមប្រឹក្សារាជធានីភ្នំពេញ

អតីតសមាជិកព្រឹទ្ធសភា

---

**ទីស្នាក់ការបណ្តោះអាសន្នផ្ទះលេខ: 10B ផ្លូវលេខ 234 សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ**
**ទូរស័ព្ទលេខ: (៨៥៥) ១២ ៥០៨ ៨៨២ / ០៩៩ ៦៣៩ ៦៦០**
E-mail: senthach2000.com: Website: http//khmerkromngo.org

Chivan

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលារាជធានីភ្នំពេញ**

**លេខ :** ៣០៧ ឆត.អធិ

រាជធានីភ្នំពេញ , ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១០

**ជំរាបមក**

**លោក ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម** ✓

**<u>កម្មវត្ថុ</u>** : ស្តីពីសំណើសុំពហុកីឡាដ្ឋានជាតិអូឡាំពិក ធ្វើបុណ្យរាប់បាត្រព្រះសង្ឃ ១៩៨៩ អង្គ ។

**<u>យោង</u>** : លិខិតលេខ ១១/១០ ស.ខ.ក.ក ចុះថ្ងៃទី ២៦/៥/២០១០ របស់សហគមន៍ខ្មែរកម្ពុជាក្រោម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកជ្រាបថា : ចំពោះសំណើសុំពហុកីឡាដ្ឋានជាតិអូឡាំពិក ឬកន្លែងផ្សេងណាមួយទៀត សំរាប់រៀបចំពិធីបុណ្យរាប់បាត្រព្រះសង្ឃ ចំនួន ១៩៨៩អង្គ នៅថ្ងៃទី ០៨/៦/២០១០ នោះ សាលារាជធានីភ្នំពេញសូមឲ្យលោកស្នើសុំទៅក្រសួងអប់រំ យុវជន និងកីឡា ព្រោះពហុកីឡាដ្ឋានជាតិអូឡាំពិក ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំ យុវជន និងកីឡា បើក្រសួងអនុញ្ញាតអោយ សាលារាជធានីភ្នំពេញពុំយល់ទាស់ទេ តែក្នុងករណីក្រសួងមិនអនុញ្ញាត សាលារាជធានីភ្នំពេញអនុញ្ញាតឲ្យប្រារព្ធពិធីនេះនៅក្នុងទីស្នាក់ការរបស់សហគមន៍ខ្មែរកម្ពុជាក្រោម ស្ថិតនៅផ្ទះលេខ ១០B ផ្លូវលេខ ២៣៨ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

អាស្រ័យហេតុនេះ សូមលោកជ្រាប ។

<u>ចម្លងជូន</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងអប់រំ យុវជន និងកីឡា
  (ដើម្បីជូនជ្រាបជាព័ត៌មាន)
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- សាលាខណ្ឌដូនពេញ
- សាលាខណ្ឌចំការមន
- សាលាខណ្ឌទួលគោក
- ឯកសារ-កាលប្បវត្តិ

អភិបាលរាជធានីភ្នំពេញ

A៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣-៧២២ ៧៣៩ / [illegible] ៩២៥ ទូរសារ : (៨៥៥) ២៣-៧២៥ ៦២៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ** ១៩៤៤ **អយក.រវ**

*រាជធានីភ្នំពេញ ថ្ងៃទី០១ ខែ មិថុនា ឆ្នាំ ២០១០*

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ជម្រាបមក**

**លោកនាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម**

**កម្មវត្ថុ:** ករណីស្នើសុំប្រើប្រាស់ទីតាំងពហុកីឡាដ្ឋានជាតិអូឡាំពិកធ្វើបុណ្យរាប់បាត្រព្រះសង្ឃ១៩៤៩ អង្គ

**យោង:** លិខិតលេខ ១២/១០ ស.ខ.ក.ក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១០ របស់សហគមន៍ខ្មែរកម្ពុជាក្រោម

តបតាមកម្មវត្ថុ និងយោងខាងលើ ក្រសួងសូមជម្រាប **លោកនាយក** មេត្តាជ្រាបថា ចាប់ពីថ្ងៃទី ០៣ ខែ មិថុនា ដល់ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ២០១០ ពហុកីឡាដ្ឋានជាតិអូឡាំពិកជាប់រវល់ក្នុងការប្រកួតកីឡាប៉េងប៉ុងអន្តរជាតិ ដែលមាន ១០ ប្រទេសចូលរួម និងកម្មវិធីប្រកួតថ្នាក់ជាតិផ្សេងៗទៀត ជាបន្តបន្ទាប់តាមកម្មវិធីដែលបានគ្រោងទុករួចមកហើយ ។ ហេតុនេះក្រសួងអប់រំ យុវជន និងកីឡាពុំអាចអនុញ្ញាតផ្តល់ទីតាំងពហុកីឡាដ្ឋានជាតិអូឡាំពិក សម្រាប់រៀបចំពិធីដូចជម្រាបជូនក្នុងកម្មវត្ថុខាងលើបានឡើយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ ខ្ញុំសូម **លោកនាយក** មេត្តាជ្រាប និងមេត្តាយោគយល់ដល់ក្រសួងតាមការគួរ ។

សូម **លោកនាយក** មេត្តាទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ត.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**អ៊ិន ថេរ**

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- សាលារាជធានីភ្នំពេញ

(ដើម្បីជូនជ្រាបជាព័ត៌មាន)

-ឯកសារ - កាលប្បវត្តិ

អាសយដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ៤២៧ ៣៩៦ / ៤២៦ ៩៥១ / ២១២ ៥១២
E-mail: crsmeys@camnet.com.kh / yangyano@camnet.com.kh Web Site: www.moeys.gov.kh

**សមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម**
**KHMER KAMPUCHEA KROM BUDDHIST MONK ASSOCIATION**
**ភូមិ ទ្រា ក្រុម ទី ៩ សង្កាត់ ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ**
**Trea village, Gr. 9, Sangkat Stung Meanchey, Khan Mean Chey, Phnom Penh.**
**លេខៈ...៣៧...សមពខកក-២០១០.......... Tel: 012 918 692**

# សូមចំរើនពរជូន
# ឯកឧត្តមអភិបាលរាជធានីភ្នំពេញ

*កម្មវត្ថុ:* ជូនដំណឹងស្តីអំពីការធ្វើបុណ្យរាប់បាត្រព្រះសង្ឃ១៩៨៩អង្គ

តបតាមកម្មវត្ថុ អាត្មាភាពសូមចំរើនពរជំរាបជូនឯកឧត្តមអភិបាលរាជធានីភ្នំពេញមេត្តាជ្រាបថា នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ នៅវត្តសាមគ្គីរង្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ មានធ្វើពិធីបុណ្យ រាប់បាត្រព្រះសង្ឃចំនួន១៩៨៩អង្គ ដើម្បីឧទ្ទិសកុសលប្រគេនព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ថ្វាយព្រះវិញ្ញាណក្ខន្ធព្រះវីរព្រះមហាក្សត្រ និងវិញ្ញាណក្ខន្ធវីរបុរស-នារីខ្មែរស្នេហាជាតិទាំងអស់ ដែលបានពលីជីវិតក្នុងបុព្វហេតុជាតិ សាសនា និងទឹកដីខ្មែរ ជាពិសេសពូជសាសន៍ សាសនា និងទឹកដីខ្មែរកម្ពុជាក្រោម។

កម្មវិធីបុណ្យ និងប្រព្រឹត្តិទៅចាប់ពីម៉ោងម៉ោង៥ល្ងាចថ្ងៃទី០៣ ខែមិខុនា ឆ្នាំ២០១០ និមន្តព្រះសង្ឃសម្តែងព្រះបរិត្ត ព្រឹកឡើងថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ ចាប់ពីម៉ោង៧ព្រឹករហូតដលម៉ោង១២ថ្ងៃត្រង់ ប្រារព្ធពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន១៩៨៩អង្គ ក្រោមព្រះអធិបតីភាពសម្តេចស៊ីសុវត្ថិ ពង្សនារី មុនីពង្ស ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ នៃព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។

អាស្រ័យហេតុនេះសូមឯកឧត្តមមេត្តាជ្រាប និងជួយចាត់ចែងកិច្ចការពារសន្តិសុខ ដល់ពិធីបុណ្យដូចបានជំរាបជូនខាងលើដោយអនុគ្រោះ។

សូមឯកឧត្តម ទទួលនូវការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅបំផុតអំពីអាត្មាភាព។

*រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០K*

ប្រធានសមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម

ភិក្ខុវិជ្ជារតនបញ្ញា ព្រះមហា ស៊ឿង សឺន
ព្រះចៅអធិការវត្តសាមគ្គី រង្សី